# មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ បង្ហាញថា

# មគ្គុទ្ទេសក៍ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់មាតាបិតាក្នុងនាមជាដៃគូ ថ្នាក់ទី 1

មណ្ឌលសិក្សាធិការយូនីហ្វៃដ៍អូកឡិនដ៍ ជឿទៅលើសំណុំមួយនៃជំនឿស្នូលអំពីគ្រួសារដែលយើងបម្រើជូនជារៀងរាល់ថ្ងៃ។

**ជំនឿគោល #1** មាតាបិតាទាំងអស់មានក្ដីស្រមៃសម្រាប់កូនរបស់ខ្លួន និងចង់ឲ្យពួកគេល្អ
**ជំនឿគោល #2** ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់ចំពោះសមិទ្ធិផលនៃការសិក្សា
**ជំនឿគោល #3** មាតាបិតាទាំងអស់អាចគាំទ្រការសិក្សារបស់កូនរបស់ពួកគេបាន
**ជំនឿគោល #4** ការទទួលខុសត្រូវក្នុងការបង្កើតភាពជាដៃគូរវាងសាលា និងផ្ទះ ផ្អែកជាចំបងលើបុគ្គលិកសាលា ជាពិសេសថ្នាក់ដឹកនាំសាលា។

ពីព្រោះយើងប្រកាន់យកនូវជំនឿគោលលើការចូលរួមរបស់គ្រួសារ យើងបានបង្កើតសម្ភារ និងធនធានដើម្បីធានាថា គ្រួសារទាំងអស់យល់អំពី**ស្តង់ដារមុខវិជ្ជាស្នូល** និងអាចគាំទ្រការសិក្សានៅក្នុងផ្ទះ។ ធនធានទាំងនេះរួមមាន កញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ (*Common Core Backpack*) ដែលទាំងនោះគឺជាសកម្មភាពដែលមាតាបិតាអាចប្រើនៅផ្ទះ ដើម្បីពង្រឹងស្តង់ដារនៃមុខវិជ្ជាគោលទាំងនោះ។

| **តើអ្វីគឺស្តង់ដារមុខវិជ្ជាស្នូល?** | **ហេតុអ្វីត្រូវការមុខវិជ្ជាស្នូល** |
|---|---|
| កាលពីមុន រដ្ឋនិមួយៗមានកម្រិតស្តង់ដារអប់រំរបស់ខ្លួន។ ចំណុចនេះបានបង្កឲ្យមានការភាន់ច្រលំ និងក្ដីបារម្ភណ៍អំពីថាតើសិស្សរបស់យើងត្រៀមខ្លួនសម្រាប់ចូលមហាវិទ្យាល័យ និងអាជីពការងារនៅក្នុងពេលបញ្ចប់ការសិក្សាពីវិទ្យាល័យ ឬអត់។ រដ្ឋកាលីហ្វ័រញ៉ា បានអនុម័តនូវស្តង់ដារមុខវិជ្ជាស្នូលនៅក្នុងឆ្នាំ 2010។<br><br>ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋ (CCSS) គឺជាការរំពឹងទុកនៃការសិក្សាមួយនៅក្នុងសិល្បៈភាសាអង់គ្លេស និងគណិតវិទ្យា ដែលបានបង្កើតឡើងដើម្បីត្រៀមសិស្សថ្នាក់ទី12 (K-12) ឲ្យចូលរៀនមហាវិទ្យាល័យ និងជោគជ័យអាជីពការងារ។ CCSS បង្ហាញឲ្យដឹងអំពីអ្វីដែលត្រូវបានរំពឹងពីសិស្ស នៅតាមកម្រិតនិមួយៗ ដោយឲ្យសិស្ស មាតាបិតា គ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលា ស្ថិតនៅក្នុងទីតាំងតែមួយដូចគ្នា ខណៈពេលកំពុងធ្វើការឆ្ពោះទៅរកគោលដៅរួមគ្នា។ | ស្តង់ដារមុខវិជ្ជាស្នូលរបស់រដ្ឋគឺមានសារសំខាន់ពីព្រោះមុខវិជ្ជាទាំងនេះនឹងជួយកុមារទាំងអស់ មិនថាពួកគេជានរណានោះទេ សុទ្ធតែរៀនជំនាញដូចគ្នាសម្រាប់ត្រៀមចូលមហាវិទ្យាល័យ និងអាជីពការងារ។ ពួកគេបង្កើតការរំពឹងទុកច្បាស់លាស់មួយសម្រាប់អ្វីដែលកូនរបស់អ្នកគួរដឹង និងអាចធ្វើ នៅក្នុងផ្នែកសំខាន់ផ្សេងៗ៖ អក្ខរកម្ម (**ការអាន សរសេរ និយាយ** និង**ស្តាប់**លើគ្រប់ផ្នែកនៃមុខវិជ្ជា) និង**គណិតវិទ្យា**។<br><br>ប្រសិនអ្នកដឹងការរំពឹងទុកទាំងនោះគឺជាអ្វី ក្រោយមកអ្នកអាចជួយកូនរបស់អ្នករៀបចំខ្លួន ពីព្រោះលោកអ្នកគឺជាគ្រូដំបូងរបស់កូនលោកអ្នក។<br><br>សិស្សរបស់យើងគឺជាអ្នកវិទ្យាសាស្ត្រ អ្នកស្រាវជ្រាវ អ្នកគ្រប់គ្រង និងអ្នករចនាប្លង់នាពេលអនាគត។ ពួកគេគឺជាអ្នកដោះស្រាយបញ្ហា និងសហការ។ មុខវិជ្ជាស្នូលត្រៀមធ្វើឲ្យពួកគេប្រកួតប្រជែងជាមួយ<br>មិនមែនត្រឹមតែមិត្តភ័ក្រ្តជនជាតិអាមេរិកកាំងនៅក្នុងរដ្ឋផ្សេងទៀតប៉ុណ្ណោះទេ ប៉ុន្តែជាមួយសិស្សដែលមកពីបណ្ដាប្រទេសនានាលើពិភពលោក។ |

## តើគ្រួសារអាចគាំទ្រជោគជ័យរបស់សាលាដោយរបៀបណា?

ភាពជាដៃគូរជាមួយគ្រួសារគឺមានសារសំខាន់សម្រាប់ជោគជ័យនៃការសិក្សា។ និយាយយ៉ាងសាមញ្ញ សាលាមិនអាចអប់រំសិស្សតែម្នាក់ឯងបានទេ។ តើគ្រួសារអាចធ្វើជាដៃគូរជាមួយសាលាបានដោយរបៀបណា?

1. ដឹងពីអ្វីដែលកូនរបស់អ្នកគួររៀននៅថ្នាក់ទី 1
2. សួរគ្រូថាតើកូនរបស់អ្នកមានទទួលជំនាញដែលបានបង្រៀនហើយឬនៅ
3. សួរថាតើលោកអ្នកអាចគាំទ្រការសិក្សានៅផ្ទះដោយរបៀបណា។ សួររកសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោលទាំងអស់ *(Common Core Backpack)* ដែលគឺជាសកម្មភាព ដែលមាតាបិតាប្រើនៅផ្ទះជាមួយកូន ដើម្បីទទួលបានចំណេះដឹងពីស្តង់ដារមុខវិជ្ជាស្នូលទាំងនោះ។
4. អាន អាន អាន។ សូមឲ្យកូនរបស់លោកអ្នកអានជារៀងរាល់ថ្ងៃ និងសួរសំណួរទៅពួកគេ។ ក្រោយមកទៀត ឲ្យពួកគេទៅអានអត្ថបទដើម្បីឆ្លើយសំណួរ "តើអ្នកដឹងដោយរបៀបណា?
5. ត្រូវប្រាកដថា កូនរបស់លោកអ្នកគឺកំពុងអានសៀវភៅដែលមិនមែនជាប្រលោមលោកប្រឌិត ជាញឹកញាប់។

# ស្តង់ដារមុខវិជ្ជាស្នូលរួមសម្រាប់ថ្នាក់ទី 1

នេះគឺជាបំណិន **សិល្បៈភាសាអង់គ្លេស** សំខាន់មួយចំនួនដែលត្រូវយកមកបង្រៀននៅក្នុងថ្នាក់ទី 1។ សម្រាប់តារាងស្តង់ដារមុខវិជ្ជាស្នូលរដ្ឋកាលីហ្វ័រញ៉ា សូមចូលទៅគេហទំព័រក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/).

មានសកម្មភាពពីកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល សម្រាប់ស្តង់ដារមុខវិជ្ជាស្នូលនិមួយដែលមានរៀបរាប់ក្នុងបញ្ជីខាងក្រោម:

| ស្តង់ដារមុខវិជ្ជាស្នូលរួម | | ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច... |
|---|---|---|
| RL.1.1 | សួរ និងឆ្លើយសំណួរអំពីចំណុចពិស្តារសំខាន់ៗនៅក្នុងអត្ថបទ | រៀបរាប់អំពីនរណា អ្វីមួយ ទីកន្លែង ពេលវេលា មូលហេតុ និងរបៀប បន្ទាប់ពីបានអានរឿងចប់ |
| RL.1.2 | ពិពណ៌នារឿងឡើងវិញ រួមមានចំណុចពិស្តារសំខាន់ៗ និងបង្ហាញអំពីការយល់ពីខ្លឹមសារគោល ឬមេរៀន | ប្រាប់រឿងឡើងវិញ |
| RL.1.3 | ពិពណ៌នាអំពីតួអង្គ ឈុតឆាក និងព្រឹត្តិការណ៍សំខាន់ៗនៅក្នុងសាច់រឿងដោយប្រើចំណុចពិស្តារសំខាន់ៗ។ | ប្រាប់ពីសាច់រឿង ឈុតឆាក និងអ្វីដែលបានកើតឡើងនៅក្នុងរឿង។ |
| RI.1.1 | សួរ និងឆ្លើយសំណួរអំពីចំណុចពិស្តារសំខាន់ៗនៅក្នុងអត្ថបទ | រៀបរាប់អំពីនរណា អ្វីមួយ ទីកន្លែង ពេលវេលា មូលហេតុ និងរបៀប បន្ទាប់ពីបានអានរឿងពិត ចប់ |
| RI.1.2 | បង្ហាញអំពីប្រធានបទសំខាន់ៗ និងពិពណ៌នាឡើងវិញនូវចំណុចពិស្តារសំខាន់ៗនៃអត្ថបទ | រកប្រធានបទសំខាន់ និងភាពពិស្តារនៅក្នុងផ្នែកនៃរឿងពិត |
| RI.1.3 | ពិពណ៌នាទំនាក់ទំនងរវាងបុគ្គលពីរនាក់ ព្រឹត្តិការណ៍ គំនិត ឬបំណែកនៃព័ត៌មានផ្សេងៗនៅក្នុងអត្ថបទ។ | ភ្ជាប់ និងពិពណ៌នាអំពីទំនាក់ទំនងរវាងបុគ្គលពីរនាក់ ព្រឹត្តិការណ៍ ឬគំនិតនៅក្នុងរឿងពិត។ |
| RL.1.5 | ពន្យល់ភាពផ្សេងគ្នារវាងសៀវភៅដែលប្រាប់អំពីរឿង និងសៀវភៅដែលផ្តល់ព័ត៌មាន ដោយដកស្រង់ពីប្រភេទអត្ថបទផ្សេងៗគ្នា។ | ប្រាប់ភាពផ្សេងគ្នារវាងរឿងប្រឌិត និងរឿងពិត |
| RL.1.6 | បង្ហាញថាតើនរណាគឺកំពុងប្រាប់រឿងនៅក្នុងផ្នែកផ្សេងៗក្នុងអត្ថបទ | រៀបរាប់អំពីនរណាដែលកំពុងប្រាប់រឿង |
| RI.1.5 | ដឹង និងប្រើសំណង់ឃ្លានៃអត្ថបទផ្សេងៗ (ឧ. លំដាប់សាច់រឿង) និង ប្រភេទអត្ថបទ (ឧ. ចំណងជើង មាតិកា សន្ទានុក្រម បញ្ជីអេឡិចត្រូនិក និងរូបសញ្ញា) ដើម្បីដាក់ការពិតសំខាន់ៗ ឬព័ត៌មាននៅក្នុងអត្ថបទ។ CA | ប្រើប្រភេទអត្ថបទដើម្បីជួយឲ្យខ្ញុំយល់អំពីរឿងពិត |
| RI.1.6 | បង្ហាញភាពផ្សេងគ្នារវាងព័ត៌មានដែលផ្តល់ជូនដោយរូបភាព ឬការពន្យល់ផ្សេងៗ និងព័ត៌មានដែលផ្តល់តាមរយៈពាក្យដែលមាននៅក្នុង អត្ថបទ។ | ប្រើពាក្យ និងរូបភាពដើម្បីជួយឲ្យខ្ញុំយល់រឿងពិត |
| RL.1.7 | ប្រើការពន្យល់ និងភាពពិស្តារនៅក្នុងរឿងដើម្បីពិពណ៌នាតួអង្គ ឈុតឆាក ឬព្រឹត្តការណ៍។ | ប្រើពាក្យ និងរូបភាពដើម្បីជួយខ្ញុំប្រាប់អំពីតួអង្គ វគ្គ និងឈុតឆាកនៃរឿង |
| RI.1.8 | បង្ហាញអំពីមូលហេតុ ដែលអ្នកនិពន្ធផ្តល់ ដើម្បីគាំទ្រចំណុចនៅក្នុងអត្ថបទ | ខ្ញុំអាចរកមូលហេតុដើម្បីគាំទ្រគោលគំនិតសំខាន់ៗនៃរឿងពិត |
| RL.1.10 | ដោយមានការផ្តល់ជូននូវគន្លឹះថ្មីៗ និងការគាំទ្រ សូមអានអត្ថបទព័ត៌មានសម្រាប់ថ្នាក់ទី1 ឲ្យបានត្រឹមត្រូវ<br>a. ពង្រឹងចំណេះដឹងដំបូងអំពីព័ត៌មាន និងព្រឹត្តិការណ៍នៅក្នុងអត្ថបទ<br>b. សូមបញ្ជាក់ការទាយទុកអំពីអ្វីដែលនឹងកើតឡើងនៅក្នុងអត្ថបទ | អាន និងស្វែងយល់សៀវភៅរឿងថ្នាក់ទី1 |
| RF.1.1 | បង្ហាញឲ្យយល់ពីរចនាសម្ព័ន្ធ និងលក្ខណៈគោលនៃឯកសារដែលត្រូវបោះពុម្ព<br>a. ទទួលស្គាល់លក្ខណៈផ្សេងគ្នានៃប្រយោគ (ឧ. ពាក្យដំបូង អក្សរធំ និងវណ្ណយុត្តិសញ្ញា ដែលប្រើនៅចុងប្រយោគ) | ប្រើប្រភេទអត្ថបទធម្មតាដើម្បីជួយគាត់អាន (រកពាក្យដំបូង អក្សរធំ និងវណ្ណយុត្តិសញ្ញា) |
| RF.1.3 | ដឹង និងអនុវត្តការបញ្ចេញសម្លេងតាមកម្រិតថ្នាក់ និងជំនាញនៃការវិភាគពាក្យដោយបកស្រាយពាក្យនៅដាច់ដោយឡែក និងក្នុងអត្ថបទ។ CA | ចូរអានពាក្យថ្នាក់ទី1 |
| RF.1.4 | អានឲ្យបានច្បាស់លាស់ និងរលូន ដើម្បីស្វែងយល់ | អានជាមួយនឹងសំណង់ឃ្លា អានឲ្យបានច្បាស់លាស់ និងអានឡើងវិញដើម្បីស្វែងយល់ថាពាក្យមានន័យដូចម្តេច។ |

# ស្តង់ដារមុខវិជ្ជាស្នូល សម្រាប់ថ្នាក់ទី1

នេះគឺជាបំណិន **<u>គណិតវិទ្យា</u>** សំខាន់ៗដែលបង្រៀននៅថ្នាក់ទី1។ សម្រាប់បញ្ជីស្តង់ដារមុខវិជ្ជាស្នូលនៃរដ្ឋកាលីហ្វ័រញ៉ា សូមចូលទស្សនាគេហទំព័រក្រសួងអប់រំរដ្ឋកាលីហ្វ័រញ៉ា (http://www.cde.ca.gov/re/cc/).

មានសកម្មភាពកញ្ចប់នៃសៀវភៅសម្រាប់មុខវិជ្ជាគោល (Common Core Backpack) សម្រាប់ស្តង់ដារមុខវិជ្ជាស្នូលនិមួយៗ ដែលមានដូចខាងក្រោម៖

| **ស្តង់ដារមុខវិជ្ជាស្នូលរួម** | | **ជាទូទៅ វាមានន័យថា កូនរបស់អ្នកអាច...** |
|---|---|---|
| 1.OA.1 | ប្រើលេខបូក និងលេខដកនៅក្នុងចំនួនចន្លោះពី 20 ដើម្បីដោះស្រាយលំហាត់ជាពាក្យដែលពាក់ព័ន្ធនឹងការបូកបន្ថែម ដកចេញ ដាក់ចូលគ្នា បញ្ចូល និងប្រៀបធៀបជាមួយនឹងអញ្ញាតនៅគ្រប់ទីតាំងទាំងអស់ ឧ. ដោយ ប្រើប្រាស់វត្ថុ គំនូរ និងសមីការដែលមាននិមិត្តសញ្ញាសម្រាប់លេខមិនស្គាល់ ដើម្បីតាងជាចំណោទ ។ | ប្រើយុទ្ធសាស្ត្រ ដើម្បីដោះស្រាយចំណោទជាពាក្យដោយប្រើវិធីបូក និងវិធីដក។ |
| 1.OA.2 | ដោះស្រាយលំហាត់ជាពាក្យ ដែលសុំឲ្យមានការបូកបញ្ចូលលេខចំនួនបី ដែលផលបូកគឺតិចជាង ឬស្មើនឹង 20 ឧ. ដោយ ប្រើប្រាស់វត្ថុ គំនូរ និងសមីការដែលមាននិមិត្តសញ្ញាសម្រាប់លេខមិនស្គាល់ ដើម្បីតាងជាចំណោទ ។ | ដោះស្រាយចំណោទជាពាក្យដោយបន្ថែមចំនួនគត់បី។ |
| 1.NBT.1 | រាប់ដល់លេខ 120 ចាប់ពីលេខណាមួយដែលតិចជាលេខ120។ នៅក្នុងលំដាប់នេះ អាន និងសរសេរលេខ និងតំណាងឲ្យវត្ថុមួយចំនួនដែលមានសរសេរលេខនៅពីលើ | រាប់ដល់ 120។ |
| 1.NBT.2 | យល់ថា ចំនួនពីរខ្ទង់នៃលេខពីខ្ទង់គឺតំណាងឲ្យចំនួនដប់ និងចំនួនមួយ។ យល់អំពីចំណុចខាងក្រោមជាករណីពិសេសៈ<br>a. 10 អាចត្រូវបានគិតជាបណ្តុំនៃចំនួនមួយដប់ដង ហៅថា "ខ្ទង់ដប់"<br>b. ចំនួនពី11 ដល់19 គឺរួមមានខ្ទង់ដប់ បូកនឹងលេខមួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី និងប្រាំបួន។<br>c. ចំនួន 10, 20, 30, 40, 50, 60, 70, 80, 90 សំដៅលើការបន្ថែមលេខមួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី និងប្រាំបួន (និងលេខសូន្យ) | ប្រាប់ថាតើមានចំនួនខ្ទង់ដប់ និងខ្ទង់រាយប៉ុន្មាននៅក្នុងលេខណាមួយ។ |
| 1.NBT.3 | ប្រៀបធៀបលេខពីរខ្ទង់ចំនួនពីរ ផ្អែកលើអត្ថន័យនៃខ្ទង់ដប់ និងមួយ ដោយកត់ត្រានូវលទ្ធផលនៃការប្រៀបធៀបជាមួយនឹងនិមិត្តសញ្ញា >, =, និង <។ | ប្រៀបធៀបចំនួនពីរខ្ទង់ ដោយប្រើ <, =, និង >។ |
| 1.NBT.5 | ផ្អែកលើលេខពីរខ្ទង់មួយ គិតស្វែងរកច្រើនលេខច្រើនជាង10 ឬតិចជាង10 ដោយពុំបាច់ពន្យល់ពីវិចារដែលបានប្រើប្រាស់ទេ។ | រកលេខច្រើនជាង10 ឬតិចជាង10 ដោយគិតនៅក្នុងខួរក្បាល របស់គេ។ |
| 1.MD.1 | បញ្ជាទិញវត្ថុចំនួនបីតាមប្រវែង ប្រៀបធៀបប្រវែងនៃវត្ថុពីរដោយប្រើវត្ថុទីបី។ | តម្រៀបវត្ថុបី តាមលំដាប់ពីវែងជាងគេទៅខ្លីជាងគេ។ |
| 1.MD.2 | បង្ហាញពីប្រវែងនៃវត្ថុជាចំនួនគត់នៃឯកតារង្វាស់ ដោយការដាក់តំរៀបវត្ថុខ្លីៗជាច្រើន (ឯកតារង្វាស់) ពីចុងមួយទៅចុងមួយ។ យល់ថា ការវាស់ប្រវែងវត្ថុមួយគឺជាចំនួននៃឯកតាប្រវែងនៃវត្ថុដែលមានទំហំដូចគ្នាដែលលាតសន្ធឹង ដោយគ្មានចន្លោះ ឬជាន់គ្នា។ កម្រិតចំណុចដែលវត្ថុនោះត្រូវបានវាស់វែងគឺលាតសន្ធឹងតាមចំនួនប្រវែងដែលគ្មានចន្លោះ និងជាន់គ្នា។ | ប្រាប់អំពីប្រវែងនៃវត្ថុដោយប្រើចំនួនគត់។ |
| 1.MD.3 | ប្រាប់ និងសរសេរពេលវេលាជាម៉ោង និងកន្លះម៉ោងដោយប្រើនាឡិកាឌីជីថល។ | ប្រាប់ និងសរសេរពេលវេលាជាម៉ោង និងកន្លះម៉ោងដោយប្រើនាឡិកា។ |
| 1.MD.4 | រៀបចំ តាង និងបកស្រាយទិន្នន័យជាបីប្រភេទ។ សួរ និងឆ្លើយ សំណួរអំពីចំនួនសរុបនៃពិន្ទុ តើមានប៉ុន្មាននៅក្នុងប្រភេទនិមួយៗ និងមានតិច ឬច្រើនប៉ុន្មានទៀតនៅក្នុងប្រភេទនិមួយៗ ជាងនៅក្នុងផ្នែកមួយផ្សេងទៀត | រៀបចំ ស្វែងយល់ និងឆ្លើយសំណួរអំពីទិន្នន័យ។ |
| 1.G.1 | បង្ហាញភាពខុសគ្នារវាងលក្ខណៈដែលមានកំណត់និយមន័យ (ឧ. ត្រីកោណគឺមានលក្ខណៈបិទជិត និង មានបីជ្រុង) ទល់នឹងលក្ខណៈដែលមិនមានកំណត់និយមន័យ (ឧ. ពណ៌ ទិសដៅ និងទំហំទាំងមូល) សង់ និងគូសរូបរាងផ្សេងៗដើម្បីបង្ហាញឲ្យឃើញនូវលក្ខណៈដែលមានកំណត់និយមន័យ។ | ប្រាប់ សង់ និងគូសរូបរាងផ្សេងៗ។ |

*ស្តង់ដារដែលមានភាពងាយស្រួលសម្រាប់មាតាបិតា ដែលដកស្រង់ពីលោក Jill និង Cathey Henry។ "I Can Standards." www.thecurricculumcorner.com. ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2012*